ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១២២៣ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃ នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៦ ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និង នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
១៧១

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ នៃនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់ទូវមុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

**ប្រការ ២.-**

ត្រូវបានកំណត់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួនបួន (០៤) ដូចខាងក្រោម ៖

- ការិយាល័យផែនការ និងគោលនយោបាយគយ
- ការិយាល័យបច្ចេកទេសគយ
- ការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា
- ការិយាល័យកិច្ចការអន្តរជាតិ

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ចដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

**ប្រការ ៣.-**

ការិយាល័យផែនការនិងគោលនយោបាយគយ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- លើកសំណើគោលនយោបាយសមស្របពាក់ព័ន្ធនឹងពាណិជ្ជកម្មអន្តរជាតិ និងចូលរួមធ្វើសេចក្តីព្រាងបទបញ្ញត្តិ និងកំណត់ផែនការពាក់ព័ន្ធនឹងការរៀបចំប្រមូលពន្ធ និងអាករគ្រប់ប្រភេទ ឲ្យបានសមស្របទៅតាមតំណាក់កាលនីមួយៗនៃការវិវត្តន៍គោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋ។
- លើកឡើងនូវផែនការជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- សិក្សា និងវិភាគបណ្តាគោលនយោបាយសេដ្ឋកិច្ចនានា ពាក់ព័ន្ធនឹងគយ។
- ចូលរួមឃ្លាំមើល និងវាយតម្លៃការអនុវត្តន៍កិច្ចប្រតិបត្តិការគយ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៤.-**

ការិយាល័យបច្ចេកទេសគយ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- គ្រប់គ្រង កសាង និងតាមដានពិនិត្យការអនុវត្តន៍បទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធនឹងតារាងពន្ធគយ ការកំណត់តម្លៃគិតពន្ធគយ ឬអាករគយលើទំនិញទាំងឡាយ

នាំចូល ការវិវត្តនៃការកំណត់ដើមកំណើតទំនិញឲ្យបានទាន់ពេលវេលា និងស្របតាមការវិវត្តន៍នៃសេដ្ឋកិច្ចជាតិ និងពាណិជ្ជកម្មអន្តរជាតិ។

- ស្រាវជ្រាវ និងកែសម្រួលជាប្រចាំនូវបញ្ជីរយោងតម្លៃគិតពន្ធ ឬអាករគយ លើទំនិញនាំចេញ នាំចូល តម្លៃប័យប័ណ្ណ អត្រាប្តូរប្រាក់តាមការកំណត់របស់ច្បាប់ និងបទបញ្ញត្តិជាធរមាន ព្រមទាំងចូលរួមត្រួតពិនិត្យ ផ្ទៀងផ្ទាត់មើលការអនុវត្តន៍នូវបណ្តាតារាង និងបញ្ជីទាំងនេះ។
- បំពេញតួនាទី ពិនិត្យ និងផ្តល់យោបល់លើការកំណត់តម្លៃគិតពន្ធ ឬអាករគយ ការកំណត់ដើមកំណើត និងការកំណត់ចំណាត់ថ្នាក់ទំនិញ និងចូលរួមផ្តល់យោបល់លើទិដ្ឋភាពបច្ចេកទេសគយពាក់ព័ន្ធផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៥.-**

ការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា មានមុខងារ និងភារកិច្ចដូចតទៅ ៖

- កសាងយុទ្ធសាស្ត្រ និងចក្ខុវិស័យគយ និងរដ្ឋាករកម្ពុជា ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យាក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- រៀបចំបទបញ្ញត្តិ និងថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងសុវត្ថិភាពផ្នែកព័ត៌មានវិទ្យា។
- រៀបចំគ្រប់គ្រងការស្រង់ប្រមូល និងរក្សាទិន្នន័យ និងស្ថិតិនៃការនាំចេញ នាំចូល។
- ប្រមូលផ្តុំទិន្នន័យទំនិញនាំចេញ នាំចូល ជាលក្ខណៈសង្ខេប ជាប្រចាំរាល់ដំណាច់ខែ ត្រីមាស ឆ្នាំនីមួយៗ។
- រៀបចំតភ្ជាប់បណ្តាញកុំព្យូទ័រនៅក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងគ្រប់គ្រងការប្រើប្រាស់ និងថែរក្សាបណ្តាញនេះ។
- សម្របសម្រួល និងចូលរួមសហការជាមួយស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល និងផ្នែកឯកជនក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើពាណិជ្ជកម្មអន្តរជាតិ ។
- ប្រមូលផ្តុំព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន ពាក់ព័ន្ធនឹងកិច្ចការគយ និងរដ្ឋាករដល់អាជីវករ និងអតិថិជន ដោយប្រើប្រាស់គ្រប់មធ្យោបាយ រួមទាំងមធ្យោបាយអេឡិចត្រូនិចផងដែរ ។
- សហការជាមួយអង្គការតំបន់ និងអន្តរជាតិ ព្រមទាំងរដ្ឋបាលគយនៃប្រទេសផ្សេងទៀតក្នុងការផ្លាស់ប្តូរព័ត៌មាន ការប្រើប្រាស់ និងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៦.-**

ការិយាល័យកិច្ចការអន្តរជាតិ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- លើកឡើងនូវយុទ្ធសាស្ត្រ និងចក្ខុវិស័យគយ និងរដ្ឋាករកម្ពុជាក្នុងបរិបទសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។
- សិក្សា និងផ្តល់អនុសាសន៍ស្តីពីការចូលរួមប្រតិបត្តិការផ្នែកគយ នៅក្នុងអង្គការតំបន់ និងពិភពលោក ព្រមទាំងជម្រុញបង្កើនទំនាក់ទំនងទ្វេភាគី ជាមួយរដ្ឋបាលគយនៃប្រទេសផ្សេងៗ។
- តាមដាន និងសម្របសម្រួលការអនុវត្តន៍នូវកាលកាតព្វកិច្ចរបស់កម្ពុជា ពាក់ព័ន្ធនឹងកិច្ចការគយ ក្រោមកិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគី។
- វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍អំពីផលប៉ះពាល់ផ្សេងៗ ដែលអាចកើតមានឡើងពីការអនុវត្តន៍កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីទាំងនោះ ជាពិសេសពាក់ព័ន្ធនឹងចំណូលពន្ធគយ ។
- សម្របសម្រួល និងចូលរួមសហការជាមួយស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ ។
- សហការជាមួយអង្គភាពពាក់ព័ន្ធនានា នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីស្រាវជ្រាវព័ត៌មាន ពាក់ព័ន្ធនឹងបទល្មើសគ្រប់ប្រភេទពីបណ្តាប្រទេសក្នុងប្រទេស និងអន្តរជាតិ ព្រមទាំងចូលរួមវិភាគ និងវាយតម្លៃហានិភ័យលើព័ត៌មានទាំងនេះ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**មាត្រា ៧.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុងដែលពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ